មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# វិចារណកថាព័ត៌មានរបស់ ម.ស.ម.ក

ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២

## ម.ស.ម.ក បង្ហាញពីការព្រួយបារម្ភចំពោះសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និងស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា

យោងតាមរបាយការណ៍របស់វិទ្យុអាស៊ីសេរី កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១២ (ចំណងជើង "អ្នកកាសែតម្នាក់ត្រូវចាប់ខ្លួនបន្ទាប់ពីរាយការណ៍អំពីបទល្មើសឈើ") រាយការណ៍ថាអ្នកកាសែតម្នាក់ត្រូវបានចាប់ខ្លួនយោងតាមដីកាពីព្រះរាជអាជ្ញាសាលាដំបូងខេត្តក្រចេះ។ របាយការណ៍មួយទៀតរបស់ វិទ្យុអាស៊ីសេរី ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ បានរាយការណ៍ថាអ្នកយកព័ត៌មានមួយរូបទៀតត្រូវបានរកឃើញថាសន្លប់ បន្ទាប់ពីការសន្និដ្ឋានរបស់នគរបាលថាជាគ្រោះថ្នាក់ចរាចរណ៍។ ករណីនៃការចាប់ខ្លួន និងគ្រោះថ្នាក់ចរាចរណ៍នេះនាំឲ្យមានការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរ។

លោក តាំង ទ្រី អ្នកយកព័ត៌មាននៃកាសែតទស្សវត្សថ្មី និងជាសមាជិកសមាគមអ្នកសារព័ត៌មានខ្មែរប្រជាធិបតេយ្យ ត្រូវបានចាប់ខ្លួនយោងតាមដីការបស់ព្រះរាជអាជ្ញាខេត្តក្រចេះ ពីបទជំរិតទារប្រាក់។ តាមការរាយការណ៍របស់ វិទ្យុអាស៊ីសេរី នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១២ លោក តាំង ទ្រី បានរាយការណ៍ទៅមន្ត្រីនគរបាលពីបទកាប់ឈើខុសច្បាប់ដែលធ្វើឡើងដោយបុគ្គលមានអំណាច។ បន្ទាប់ពីរាយការណ៍បទល្មើសនេះ លោក តាំង ទ្រី ក៏ត្រូវបានចាប់ខ្លួន ហើយលោកកំពុងតែស្ថិតនៅក្នុងពន្ធនាគារចំណែកអ្នករួមការងារជាមួយលោកបានកំពុងស្វែងរកមេធាវីដើម្បីការពាររឿងក្តីរបស់លោក។

មួយថ្ងៃបន្ទាប់ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១២ លោក វិជ័យ អានន្ទ អ្នកយកព័ត៌មានរបស់ វិទ្យុអាស៊ីសេរី ដែលបានរាយការណ៍ពីការចាប់ខ្លួនរបស់លោក តាំង ទ្រី ត្រូវបានរកឃើញថាសន្លប់នៅលើដងផ្លូវភ្ជាប់ពីខេត្តក្រចេះទៅខេត្តស្ទឹងត្រែង។ រឿងរ៉ាវលម្អិតពាក់ព័ន្ធនឹងគ្រោះថ្នាក់ចរាចរណ៍នេះមិនទាន់ត្រូវបានបង្ហាញនៅឡើយទេ ខណៈពេលនេះដែរ លោក វិជ័យ អានន្ទ នៅមិនទាន់ដឹងខ្លួននៅឡើយទេ។

**ឆ្លើយតបទៅនឹងករណីទាំងនេះ សន រ៉ាមណា មន្ត្រីសម្របសម្រួលគម្រោងសេរីភាពបញ្ចេញមតិរបស់ ម.ស.ម.ក បានមានប្រសាសន៍ថា ៖**

*"ករណីទាំងពីរនេះ គឺធ្វើឲ្យខ្ញុំមានការព្រួយបារម្ភជាខ្លាំង ហើយខ្ញុំចង់ដឹងពីព័ត៌មានលម្អិតទាក់ទងនឹងរឿងទាំងនេះ។ ដូច្នេះ ខ្ញុំសូមអំពាវនាវឲ្យមានការស៊ើបអង្កេតយ៉ាងពេញលេញ និងសមស្របចំពោះករណីទាំងពីរនេះ។ ខ្ញុំក៏សូមយកឱកាសនេះដើម្បីជាការរំលឹកដល់រដ្ឋាភិបាល និងអាជ្ញាធរអំពីករណីរបស់លោក ហង្ស សេរីឧត្តម ដែលជាអ្នកយកព័ត៌មានមួយរូបត្រូវបានសម្លាប់កាលពីដើមខែកញ្ញា ឆ្នាំ២០១២ ដែលបច្ចុប្បន្ននៅមិនទាន់មានការរកឃើញអ្វីថ្មីនៅឡើយទេ។ ខ្ញុំគិតថាអ្នកយកព័ត៌មាន គួរតែទទួលបានការការពារច្រើនជាងនេះពីរដ្ឋាភិបាល ដោយសារតែពួកគេគឺជាប្រភពព័ត៌មានសំខាន់សម្រាប់*

*ប្រជាពលរដ្ឋ។ ប្រសិនបើសេរីភាពរបស់ពួកគេត្រូវបានគាបសង្កត់ ដូច្នេះតើពួកគេនឹងអាចធ្វើការងាររបស់ពួកគេឲ្យបានសមរម្យដោយរបៀបណា?"*

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖ កញ្ញា សន រ៉ាមណា តាមរយៈទូរសព្ទ+៨៥៥ (០) ១៧ ៦៥ ៥៥៩១ ឬ អ៊ីម៉ែល ៖ ramansorn@cchrcambodia.org ឬទីប្រឹក្សាជាន់ខ្ពស់ លោក រ៉ូប៊ឺត ហ្វីនច៍ តាមរយៈទូរសព្ទ +៨៥៥ (០) ៧៨ ៨០ ៩៩ ៦០ ឬអ៊ីម៉េល robert.finch@cchrcambodia.org ។

<u>បណ្ណាធិការ</u>

ម.ស.ម.ក ត្រូវបានបង្កើតឡើងនៅក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិករបស់ ដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អ៊ីហ្វិក) ដែលជាបណ្តាញសកលដើម្បីការបញ្ចេញមតិដោយសេរី។

គេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានរង្វាន់ប្រចាំឆ្នាំ២០១១របស់មូលនិធិនៃការបង្កើតថ្មីសម្រាប់សង្គមព័ត៌មានវិទ្យា ក្នុងចំណាត់ថ្នាក់នៃ សិទ្ធិ និងសេរីភាព។#